សិទ្ធិរបស់អ្នកជម្ងឺខាងសុខភាពខួរក្បាល

MOSAIC FOREST

Alice Washington, 2004

អ្នកជម្ងឺខាងសុខភាពខួរក្បាល មានសិទ្ធិច្បាប់ស្មើគ្នា ដែលធានារ៉ាប់រង សម្រាប់មនុស្សគ្រប់រូប ដោយច្បាប់នានា និងច្បាប់រដ្ឋធម្មនុញ្ញរបស់សហរដ្ឋ និងរដ្ឋខាលីហ្វញ៉ា ។

លោកអ្នកមានសិទ្ធិ ៖

- ដើម្បីទទួលការថែទាំដែលប្រកបទៅដោយ សេចក្តីមេត្តា, សេចក្តីថ្លៃថ្នូរ, និងជាអាថ៌កំបាំង
- ដើម្បីឲ្យរួចផុតពីអំពើអាក្រក់ អានរួមទាំង ការចាប់ទប់ឲ្យនៅស្ងៀមដោយប្រើកម្លាំងហួសហេតុ ឬមិនចាំបាច់, ការប្រើថ្នាំពេទ្យ, ការទុកឲ្យនៅតែ ម្នាក់ឯង, ការធ្វើទុកទោស, និង ការមិនយក ចិត្តទុកដាក់
- ដើម្បីទទួលពត៌មានអំពីការព្យាបាល ហើយ ដើម្បីចូលរួម ក្នុងការរៀបចំការព្យាបាល របស់លោកអ្នក
- ដើម្បីយល់ព្រម ឬបដិសេធ ដើម្បីព្រមព្រៀងតាម ការព្យាបាល, លើកលែងតែមានភាពអាសន្ន ដែលបានឲ្យអត្ថន័យតាមច្បាប់ ឬ ការសម្រេច តាមច្បាប់ថាអសមត្ថភាព
- ដើម្បីទទួលកិច្ចការបំរើតាមមជ្ឈមណ្ឌលបំរើភ្ញៀវ ដែលបានរៀបចំដើម្បីបំរើគោលបំណងផ្ទាល់ខ្លួន, សេចក្តីត្រូវការផ្សេងៗ, ការព្រួយបារម្ភ, កំឡាំង, ការលើកទឹកចិត្ត និង ភាពពិការ របស់លោកអ្នក
- ដើម្បីទទួលកិច្ចការបំរើខាងការព្យាបាល ដើម្បីបង្កើនសមត្ថភាពរបស់លោកអ្នក ដើម្បីរស់នៅម្នាក់ឯងបានប្រសើរជាងមុន
- ដើម្បីទទួលការថែទាំ និងការព្យាបាលតាម វិជ្ជាពេទ្យភ្លាមៗ
- ដើម្បីទទួលកិច្ចការបំរើ និងពត៌មានជាភាសាដែល លោកអ្នកអាចយល់ ហើយ ដែលយល់ដឹងអំពី ភាពផ្សេងៗគ្នាខាងវប្បធម៌ និងសេចក្តីត្រូវការ ពិសេសៗ
- ដើម្បីរក្សាទុក ហើយប្រើទ្រព្យសម្បត្តិផ្ទាល់ខ្លួន របស់លោកអ្នក អានរួមទាំងសម្ភារៈប្រើនៅក្នុងបង្គន់
- ដើម្បីឲ្យមានកន្លែងទុកទ្រព្យសម្បត្តិផ្ទាល់ខ្លួន សម្រាប់ប្រើតែម្នាក់ឯង
- ដើម្បីរក្សាទុក ហើយចំណាយលុយចំនួនសមហេតុ សមផលរបស់លោកអ្នក សម្រាប់ទិញវត្ថុបន្តិចបន្តួច
- ដើម្បីឲ្យមានវិធីទៅរកទូរស័ព្ទ ដើម្បីទូរស័ព្ទចេញ ហើយទទួលទូរស័ព្ទជាសម្ងាត់ ឬឲ្យមានគេទូរស័ព្ទ ជូនលោកអ្នក
- ដើម្បីឲ្យមានសម្ភារៈសរសេរសំបុត្រ និងតែម ដើម្បីផ្ញើចេញ ហើយទទួលការទាក់ទង ដោយគ្មាន គេបើកសំបុត្រមើល
- ដើម្បីស្លៀកពាក់ខោអាវដោយខ្លួនឯង
- ដើម្បីឲ្យមានការទាក់ទងក្នុងសង្គម, ការចូលរួម ក្នុងសកម្មភាពតាមសហគមន៍, ការហាត់ប្រាណ និងឱកាសកំសាន្ត
- ដើម្បីទទួលភ្ញៀវ រៀងរាល់ថ្ងៃ
- ដើម្បីជួប ហើយទទួលជំនួយពីអ្នកគាំទ្រអ្នកជម្ងឺ ដែលមានការទាក់ទងជាមួយមន្ទីរព្យាបាលផ្ទាល់ ឬមិនផ្ទាល់ ឬ ការទទួលខុសត្រូវខាងចាត់តែងឲ្យ មនុស្សដែលបានទទួលកិច្ចការបំរើខាងសុខភាព ខួរក្បាល
- ដើម្បីឲ្យមានការអនុវត្ត និងសេរីភាពខាងសាសនា
- ដើម្បីចូលរួមក្នុងកម្មវិធីសមរម្យខាងការអប់រំ ដែលគាំទ្រដោយសាធារណៈជន
- ទ្យ បេ ចរេ ចរ្យម ហាហ៊ារដៀស ចរ្យចេដុរសេ
- ដើម្បីឲ្យរួចផុតពីដំណើរការណ៍ដែលមាន គ្រោះថ្នាក់

សម្រាប់ពត៌មានបន្ថែម, សូមទាក់ទងអ្នកគាំទ្រសិទ្ធិ របស់លោកអ្នកជម្ងឺប្រចាំស្រុករបស់លោកអ្នក

Advocates Please
Place Your Address &
Phone Number Here

បើសិនជាលោកអ្នកមិនអាចទាក់ទងអ្នកគាំទ្រសិទ្ធិ របស់លោកអ្នកជម្ងឺប្រចាំស្រុករបស់លោកអ្នក បានទេនោះ លោកអ្នកអាចទាក់ទង ៖

Office of Patients' Rights—(916) 575-1610
Office of Human Rights—(916) 654-2327